# មាតិកា

## I.ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

២៧-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៨១ ស្តីពីការតែងតាំង ឯកឧត្តម លោកជំទាវ ចំនួន ០៣រូបជាទីប្រឹក្សាសម្តេច**ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ២១៨៣

២៧-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៨២ ស្តីពីការប្រោសព្រះរាជទានចំពោះ ឯកឧត្តម **ឃុំ គៀនទេន** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និង ពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា នូវគ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេរីវឌ្ឍន៍** ២១៨៤

២៧-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៨៤ ស្តីពី ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ២១៨៥

## II.រាជរដ្ឋាភិបាល

### អនុក្រឹត្យ

៣០-៩-២០០៤ -អនុក្រឹត្យលេខ ៦២ អនក្រ.បក ស្តីពីប្រាក់បំណាច់របស់សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ ទីប្រឹក្សា ព្រមទាំង មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ចាប់ពីថ្នាក់អនុរដ្ឋលេខាធិការឡើងទៅ ២១៨៩

៣០-៩-២០០៤ -អនុក្រឹត្យលេខ ៦៣ អនក្រ.បក ស្តីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រី រាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០០៥ ២១៩១

២៧-៩-២០០៤ -អនុក្រឹត្យលេខ ៥១០អនក្រ.តត ស្តីពីការតែងតាំង និងតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ២១៩៣

២៧-៩-២០០៤ -អនុក្រឹត្យលេខ ៥១១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២១៩៤

២៧-៩-២០០៤ -អនុក្រឹត្យលេខ ៥១២ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២១៩៦

២៨-៩-២០០៤ -អនុក្រឹត្យលេខ ៥១៣ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង នាយនគរបាលជាតិ ២១៩៧

២៨-៩-២០០៤ -អនុក្រឹត្យលេខ ៥១៤ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង នាយនគរបាលជាតិ ២១៩៨

២៨-៩-២០០៤ -អនុក្រឹត្យលេខ ៥១៥ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង នាយនគរបាលជាតិ ២១៩៩

២៨-៩-២០០៤ -អនុក្រឹត្យលេខ ៥១៦ អនក្រ.តត ស្ដីពីការតែងតាំងមុខតំណែង នាយនគរបាលជាតិ ២២០០

២៨-៩-២០០៤ -អនុក្រឹត្យលេខ ៥១៧ អនក្រ.តត ស្ដីពីការផ្ទេរភារកិច្ច នាយនគរបាលជាតិ ២២០១

២៨-៩-២០០៤ -អនុក្រឹត្យលេខ ៥១៨ អនក្រ.តត ស្ដីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ២២០២

២៨-៩-២០០៤ -អនុក្រឹត្យលេខ ៥១៩ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២២០៣

២៨-៩-២០០៤ -អនុក្រឹត្យលេខ ៥២០ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ២២០៤

២៨-៩-២០០៤ -អនុក្រឹត្យលេខ ៥២១ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ២២០៥

២៩-៩-២០០៤ -អនុក្រឹត្យលេខ ៥២២ អនក្រ.តត ស្ដីពីការតែងតាំងមុខងារនាយទាហាន ២២០៧

****អនុក្រឹត្យលេខ ៥២៣ អនក្រ.តត ( នាយកដ្ឋានរាជកិច្ចមិនទាន់បានទទួល)*

៣០-៩-២០០៤ -អនុក្រឹត្យលេខ ៥២៤ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២២០៩

៣០-៩-២០០៤ -អនុក្រឹត្យលេខ ៥២៥ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២២១១

## III. ការងារបណ្ដាក្រសួង

## ១. ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៩-៩-២០០៤ -ប្រកាសលេខ ១៩៣ MOC/M 2004 ស្ដីពី ការផ្ដល់ឡើងវិញនូវនីតិបុគ្គលិកលក្ខណៈ ២២១២

២៩-៩-២០០៤ -ប្រកាសលេខ ១៩៤ MOC/M 2004 ស្ដីពី ការផ្ដល់ឡើងវិញនូវនីតិបុគ្គលិកលក្ខណៈ ២២១៣

## ២. ទីស្ដីការរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

២៩-៩-២០០៤ -ប្រកាសលេខ ៣១៩ ប្រក.សក ស្ដីពីផែនការកំណត់ចំណតនៃជលយាន ២២១៤

## ៣. ទីស្ដីការរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

២៧-៩-២០០៤ -ប្រកាសលេខ ១៥៩ ប្រក/ជនស ស្ដីពី ឯកសណ្ឋាន និងសញ្ញាសំគាល់សំរាប់មន្ត្រី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ២២១៦

## ៤. ទីស្ដីការរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

២៧-៩-២០០៤ -ប្រកាសលេខ ០៤៨/០៤ ក.អ.ជ.ប្រក ស្ដីពីការបង្កើតអង្គភាពគ្រប់គ្រងគំរោង និងតែងតាំងនាយកគំរោង និងអ្នកផ្ដល់គំរោងសំរាប់បំរើការងារនៅអង្គភាពគ្រប់គ្រងគំរោង ក្នុងក្របខ័ណ្ឌឥណទាននៃធនាគារអភិវឌ្ឍន៍អាស៊ី ( ADB ) នៃគំរោងផ្គត់ផ្គង់ទឹកជនបទ ២២២៩

# ព្រះរាជក្រឹត្យ

នស / រកត / ០៩០៤/២៨១

## យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមិនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំង ឯកឧត្តម លោកជំទាវ ចំនួនបីរូបដូចខាងក្រោម ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ។

១-ឯកឧត្តម **សម ជារាដ្ឋ** ទទួលបន្ទុកការងារទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ

២-លោកជំទាវ **ទៅ ហួង** ទទួលបន្ទុកការងារផ្នែកមូលនិធិ

៣-លោកជំទាវ **លឹម បូរ៉ាវី** ទទួលបន្ទុកការងារផ្នែកមូលនិធិ

**មាត្រា ២:** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវ ព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ ២០០៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជឱង្ការត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

៣រល-០៤០៩.២៨៣

លេខ: ៤៣៦ ចល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ ១០ ឆ្នាំ២០០៤

**អគ្គលេខាធិការរងរដ្ឋាភិបាល**

**ណារាឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៩០៤/២៨៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

( បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម ហ៊ូ គៀនវេន
ឯកអគ្គរដ្ឋទូតវិសាមញ្ញ និង ពេញសមត្ថភាព នៃ
សាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា

នូវ

គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេរីវឌ្ឍន៍**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ ២០០៤
ក្នុងព្រះបរមនាម និង តាមព្រះរាជបន្ទូលបង្គាប់
ប្រមុខរដ្ឋស្តីទី

៣រស.០៤០៩.២៨៤

ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

លេខ ២៣៦៩ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ តុលា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈ្វាង តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៩០៤/២៨៤

## ស្តីពី
## ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ

## យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតនៈ
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេច នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើត ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ឱ្យទទួលបន្ទុកសម្របសម្រួល ដឹកនាំ តាមដាន ត្រួតពិនិត្យមើលការអនុវត្ត និង លើកសំណើជូនរាជរដ្ឋាភិបាល លើរាល់កិច្ចការនៃកំណែទម្រង់ រួមមាន ការពង្រឹងអភិបាលកិច្ចល្អ និង កំណែទម្រង់នានាលើវិស័យសំខាន់ៗរបស់បណ្តាស្ថាប័នរដ្ឋ ស្របតាមកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាល ។

**មាត្រា ២.-**

ដើម្បីបំពេញបេសកកម្ម និង សម្រេចភារកិច្ចដូចមានចែងក្នុងមាត្រា ១ ខាងលើ ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ត្រូវបានជួយជាកម្លាំងដោយក្រុមប្រឹក្សាកំណែទម្រង់មួយចំនួន ដែលទទួលខុសត្រូវផ្ទាល់ក្នុងការផ្តួចផ្តើមគំនិត និង អនុវត្តនូវកម្មវិធីកំណែទម្រង់នានា ពាក់ព័ន្ធទៅនឹងក្រសួងស្ថាប័នរបស់ខ្លួន ស្ថាប័នរដ្ឋណាមួយ ឬ ក្នុងផ្នែកណាមួយនៃវិស័យរដ្ឋបាល សេដ្ឋកិច្ច និង សង្គមកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ។

ក្រុមប្រឹក្សាកំណែទំរង់ទីមួយៗ និង ស្ថាប័នរដ្ឋដែលបំពេញការងារកំណែទំរង់ ឬ អភិបាលកិច្ចល្អ ដែលមាន ក្នុងព្រះរាជក្រឹត្យនេះ ត្រូវបង្កើតឡើង ដោយអនុក្រឹត្យ ។

ក្រុមប្រឹក្សាកំណែទំរង់ទីមួយៗ ត្រូវបានដឹកនាំដោយប្រធានមួយរូប និង មានអគ្គលេខាធិការដ្ឋានមួយធ្វើជា សេនាធិការទទួលបន្ទុកសម្របសម្រួល ដាក់ឱ្យដំណើរការ និង តាមដានជាអចិន្ត្រៃយ៍នូវការអនុវត្តការងារដែលស្ថិតនៅ ក្នុងយុត្តាធិការរបស់ប្រធាន ។

មាត្រា ៣.-

ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ អាចអញ្ជើញសមាជិករាជរដ្ឋាភិបាល ឬ ឥស្សរជនដែលមានគុណសម្បត្តិ គ្រប់គ្រាន់ មកចូលរួមក្នុងការប្រជុំរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

មាត្រា ៤.-

ដើម្បីប្រតិបត្តិបេសកកម្ម ដូចមានចែងក្នុងមាត្រាខាងលើ ឱ្យបានសម្រេចជោគជ័យ ឧត្តមក្រុមប្រឹក្សាកំណែ ទំរង់រដ្ឋ ត្រូវបំពេញមុខការ និង ភារកិច្ច ដូចតទៅ :

១- លើកសំណើស្តីពី ការបង្កើត ឬ ការផ្លាស់ប្តូរក្រុមប្រឹក្សា ឬ អង្គភាពនានា ដែលមានចរិតលក្ខណៈគតិយុត្ត ជាស្ថាប័នរដ្ឋ បំពេញការងារកំណែទំរង់តាមវិស័យនានា និង ពង្រឹងអភិបាលកិច្ច ។

២- តំរង់ទិស សម្របសម្រួល និង ត្រួតពិនិត្យសកម្មភាពការអនុវត្តន៍ការងារ និង វឌ្ឍនភាពនៃលទ្ធផល ទាំងអស់របស់ក្រុមប្រឹក្សា និង អង្គភាពទីមួយៗ ។

៣- លើកសំណើជូនរាជរដ្ឋាភិបាល ក្នុងការតាក់តែងលិខិត និង បទដ្ឋានគតិយុត្ត និង បទប្បញ្ញត្តិចាំបាច់ សំខាន់ៗ សំរាប់ដាក់ឱ្យដំណើរការកម្មវិធីកំណែទំរង់នានា និង ការពង្រឹងអភិបាលកិច្ចល្អ ។

៤- ចេញសេចក្តីសំរេច និង សេចក្តីណែនាំសំខាន់ៗ ដល់ការដាក់ឱ្យដំណើរការកម្មវិធីកំណែទំរង់នានា នៅក្នុង យុត្តាធិការរបស់ខ្លួន ។

មាត្រា ៥.-

ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ មានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- នាយករដ្ឋមន្ត្រី | ប្រធាន |
| ២- ឧបនាយករដ្ឋមន្ត្រី និង ជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- ឧបនាយករដ្ឋមន្ត្រី និង ជាសហរដ្ឋមន្ត្រីក្រសួងការពារជាតិ | សមាជិក |
| ៥- ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៦- ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួង អភិវឌ្ឍន៍ជនបទ | សមាជិក |
| ៧- ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |

៨- ប្រធានក្រុមប្រឹក្សា និង ប្រធានអង្គភាពទាំងអស់ដែលមានចែងក្នុងព្រះរាជក្រឹត្យនេះ ជាសមាជិក ។

អង្គការលេខរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ត្រូវកំណត់ទៅក្នុងឧបសម្ព័ន្ធ ដូចមានភ្ជាប់ជាមួយ ។

## ជំពូកទី ២
## អគ្គលេខាធិការដ្ឋាន

**មាត្រា ៦.-**

ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ មានអគ្គស្នងការដ្ឋានមួយ ជាអង្គភាពប្រតិបត្តិដែលត្រូវបានដឹកនាំ និង គ្រប់គ្រងដោយអគ្គស្នងការមួយរូប ។ អគ្គស្នងការដ្ឋាន ប្រើប្រាស់មន្ត្រីរាជការនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ។ អគ្គស្នងការនៃឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ មានអគ្គស្នងការរង និង ក្រុមទីប្រឹក្សាមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

អគ្គស្នងការ និង អគ្គស្នងការរង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់ប្រធានឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល គឺជាអគ្គស្នងការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

របៀបរបបការងារ និង ការបែងចែកភារកិច្ច របស់ថ្នាក់ដឹកនាំអគ្គស្នងការដ្ឋាន នៃឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ត្រូវកំណត់ដោយសេចក្តីសំរេចរបស់ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ប្រធានឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

**មាត្រា ៨.-**

អគ្គស្នងការ មានភារកិច្ចរៀបចំរបៀបវារៈនៃការប្រជុំនានារបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ផ្សព្វផ្សាយសេចក្តីសំរេច សម្របសម្រួល និង តាមដានការអនុវត្តន៍របស់ក្រុមប្រឹក្សា និង អង្គភាពនានា ហើយនិងធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារដែលសំរេចបាន ជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

## ជំពូកទី ៣
## អវសានប្បញ្ញត្តិ

**មាត្រា ៩.-**

ព្រះរាជក្រឹត្យលេខ នស / រកត / ០៣៩៩ /៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពី ការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០.-**

សម្តេចនាយករដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេច តាមស្មារតីនៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ១១.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

*ធ្វើនៅព្រះរាជវាំងភ្នំពេញ ថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ ២០០៤*

**ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាសព្វព្រះរាជហឫទ័យ**

**ប្រមុខរដ្ឋស្តីទី**

នស.០៩០៤/២៨៦

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**ហត្ថលេខា**

**សុខ អាន**

លេខ: ២២២៧ ចល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សារី គាន់**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៦៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

ប្រាក់បំណាច់របស់សមាជិករាជរដ្ឋាភិបាល
អនុរដ្ឋលេខាធិការ ទីប្រឹក្សា ព្រមទាំង មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ
ចាប់ពីថ្នាក់អនុរដ្ឋលេខាធិការឡើងទៅ

*****

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៅតាមក្រសួង ស្ថាប័ន និង រដ្ឋលេខាធិការដ្ឋាន
- យោងសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១.-**

អនុវត្តការផ្តល់ប្រាក់បំណាច់បន្ថែមលើប្រាក់បៀវត្សប្រចាំខែតាមស្មារតីអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៥ ចាប់ពី ខែ មករា ឆ្នាំ ២០០៥ តទៅ ចំពោះសមាជិក សមាជិកា រាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ ទីប្រឹក្សា រាជរដ្ឋាភិបាល អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល ទីប្រឹក្សានាយករដ្ឋមន្ត្រី-ឧបនាយករដ្ឋមន្ត្រី ព្រមទាំងមន្ត្រីរាជការស៊ីវិល និង កងកម្លាំងប្រដាប់អាវុធ ដែលមានឋានៈស្មើអនុរដ្ឋលេខាធិការឡើងទៅ ។

**មាត្រា ២.-**

ប្រាក់បំណាច់បន្ថែមលើប្រាក់បៀវត្សប្រចាំខែនេះ ត្រូវបានកំណត់ក្នុងតារាងជូនខាងក្រោមៈ

| ប្រភេទប្រាក់បំណាច់→ មុខតំណែង↓ | ប្រាក់បំណាច់ តំណាង | ប្រាក់បំណាច់ បដិសណ្ឋារកិច្ច | ប្រាក់បំណាច់ បេសកកម្ម | ប្រាក់ឈ្នួល ផ្ទះ ទឹក ភ្លើង | សរុប |
|---|---|---|---|---|---|
| នាយករដ្ឋមន្ត្រី | ១.១៣៧.៥០០៛ | ៩៦២.៥០០៛ | ៦១២.៥០០៛ | ៩៦២.៥០០៛ | ៣.៦៧៥.០០០៛ |
| ឧបនាយករដ្ឋមន្ត្រី | ៩១៨.៧៥០៛ | ៧៤៣.៧៥០៛ | ៤៨១.២៥០៛ | ៦៥៦.២៥០៛ | ២.៨០០.០០០៛ |
| ទេសរដ្ឋមន្ត្រី | ៨៣១.២៥០៛ | ៦៥៦.២៥០៛ | ៣៩៣.៧៥០៛ | ៥៦៨.៧៥០៛ | ២.៤៥០.០០០៛ |
| រដ្ឋមន្ត្រី | ៧៤៣.៧៥០៛ | ៥៦៨.៧៥០៛ | ៣០៦.២៥០៛ | ៤៨១.២៥០៛ | ២.១០០.០០០៛ |
| រដ្ឋលេខាធិការ | ៧០០.០០០៛ | ៤៨១.២៥០៛ | ២៦២.៥០០៛ | ៣០៦.២៥០៛ | ១.៧៥០.០០០៛ |
| អនុរដ្ឋលេខាធិការ | ៥២៥.០០០៛ | ៣៥០.០០០៛ | ២៦២.៥០០៛ | ២៦២.៥០០៛ | ១.៤០០.០០០៛ |

**មាត្រា ៣.-**

មន្ត្រីជាន់ខ្ពស់ដូចកំណត់ក្នុងមាត្រា ១ ដែលមានមុខតំណែងពីរ ឬ បី មានសិទ្ធិទទួលប្រាក់បំណាច់ខាងលើបានតែមួយមុខតំណែង ក្នុងតំណែងណាមួយក៏បាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៣. អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រី រាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០០៥

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកំណត់ពេលបំពេញការងារប្រចាំសប្តាហ៍របស់មន្ត្រី រាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ

# សម្រេច

**មាត្រា ១.-**

អនុញ្ញាតអោយមន្ត្រីរាជការ និយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជាទាំងអស់ បានឈប់សម្រាកការងារប្រចាំឆ្នាំ ២០០៥ តាមប្រតិទិន ដូចខាងក្រោម :

| | | | |
|---|---|---|---|
| - ថ្ងៃទី ០១ | មករា | ទិវាចូលឆ្នាំសកល | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៧ | មករា | ទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ២៣ | កុម្ភៈ | ទិវាបុណ្យមាឃបូជា | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៨ | មីនា | ទិវានារីអន្តរជាតិ | សម្រាក ០១ ថ្ងៃ |

| | | | |
|---|---|---|---|
| - ថ្ងៃទី ១៤-១៥-១៦ | មេសា | ទិវាចូលឆ្នាំខ្មែរប្រពៃណីជាតិ | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ០១ | ឧសភា | ទិវាពលកម្មអន្តរជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ២២ | ឧសភា | ទិវាបុណ្យវិសាខបូជា | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ២៦ | ឧសភា | ព្រះរាជពិធីបុណ្យច្រត់ព្រះន័ង្គល | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០១ | មិថុនា | ទិវាកុមារអន្តរជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៨ | មិថុនា | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មសម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ២៤ | កញ្ញា | ទិវាប្រកាសរដ្ឋធម្មនុញ្ញ និងព្រះរាជពិធីគ្រងរាជសម្បត្តិជាថ្មី របស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០២-០៣-០៤ | តុលា | បុណ្យភ្ជុំបិណ្ឌ | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ២៣ | តុលា | ទិវាសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ៣០-៣១តុលា និង០១វិច្ឆិកា | | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះករុណា ព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ០៩ | វិច្ឆិកា | ទិវាបុណ្យឯករាជ្យជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៥-១៦-១៧ | វិច្ឆិកា | ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ១០ | ធ្នូ | ទិវាសិទ្ធិមនុស្សអន្តរជាតិ | សម្រាក ០១ ថ្ងៃ |

**មាត្រា ២.-**

ពេលវេលាឈប់សម្រាកទាំងឡាយណាដែលត្រូវចំថ្ងៃណាមួយ នៃថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ (សៅរ៍ ឬអាទិត្យ) ត្រូវបានអោយឈប់ចំនួន ០១ ថ្ងៃ នៃថ្ងៃបន្ទាប់ជាបន្ថែមទៀត ។ ប៉ុន្តែ ក្នុងករណីត្រូវចំទាំងពីរថ្ងៃជាប់គ្នាគឺទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យនោះ ចំនួនថ្ងៃបន្ទាប់ដែលត្រូវអនុញ្ញាតអោយឈប់សម្រាកបន្ថែមជាជំនួស គឺឈប់តែ ០១ ថ្ងៃប៉ុណ្ណោះ ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥១០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំង និងតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ៣២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់នៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- លោកវរៈសេនីយ៍ទោ ជោត សារឿន អត្តលេខ ០៦១៩ ។

២- លោក អ៊ុំ សុហ៊ាលី អត្តលេខ ៥៤៧៩៩ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤*

ប្រមុខរាជរដ្ឋាភិបាល

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៥១១...អនុក្រ. ពក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
- បានឃើញព្រះរាជក្រម លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## សម្រេច

**មាត្រា១.**

ត្រូវបានបំពាក់មេដាយមាសស្ថាបនាជាតិជូនសប្បុរសជន ចំនួន ០៥ រូប ដែលបានបរិច្ចាគម៉ាស៊ីនបូមទឹក ចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រជូនប្រជាជនកម្ពុជា ដែលមានរាយឈ្មោះដូចខាងក្រោម :

១- លោក **ចាប សេខហៀង** នាយកក្រុមហ៊ុន ខាងស៊ាងលី

២- លោក **ចាប ហុងលី** នាយករងក្រុមហ៊ុន ខាងស៊ាងលី

៣- លោក **មាស ចណ្ណា** សហការី ក្រុមហ៊ុន ខាងស៊ាងលី

៤- លោក **គីម ម៉េងហួត** សហការី ក្រុមហ៊ុន ខាងស៊ាងលី

៥- លោក **គីម ម៉េងសេង** សហការី ក្រុមហ៊ុន ខាងស៊ាងលី

**មាត្រា២.** -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥១២ អនក្រ.តត

# អនុក្រឹត្យ
## ស្ដីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
- បានឃើញព្រះរាជក្រម លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

## សម្រេច

**មាត្រា១.** -

ត្រូវបានបំពាក់មេដាយមាសការងារជូនឧត្តមសេនីយ៍ទោ **មឹម សុជាត** នាយក នាយកដ្ឋាននីតិកម្ម ក្រសួងការពារជាតិ ដែលមានស្នាដៃល្អឆ្នើម ក្នុងការបំពេញភារកិច្ចជូនជាតិ មាតុភូមិ ។

**មាត្រា២.** -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ៩ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៦៣ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង នាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់នៃ ក្រសួងមហាផ្ទៃ ដូចខាងក្រោម :

១- លោកឧត្តមសេនីយ៍ត្រី **សូរ ឥវ៉ងឆាយ** អត្តលេខ ០៧២៧ បច្ចុប្បន្នអនុប្រធានទី ១ នាយកដ្ឋានបុគ្គលិក ទៅជាអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន ។

២- លោកវរៈសេនីយ៍ឯក **សេខ សិរីបុត្រ** អត្តលេខ ០២២០៥ បច្ចុប្បន្នអនុប្រធាននាយកដ្ឋានវិទ្យុទាក់ទង ទៅជាប្រធាននាយកដ្ឋាននគរបាលសេដ្ឋកិច្ច ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥១៨ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង នាយនគរបាលជាតិ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ំ រ េ ច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចខាងក្រោម :

១- លោកឧត្តមសេនីយ៍ត្រី **យ៉េម តឿន** អត្តលេខ ០១១១ បច្ចុប្បន្នអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ ទៅជា ប្រធាននាយកដ្ឋានកណ្តាលមធ្យោបាយ ។

២- លោកវរៈសេនីយ៍ឯក **សុក ធី** អត្តលេខ ០៤០៩ បច្ចុប្បន្នអនុប្រធានទី ១ នាយកដ្ឋាននគរបាលទេសចរណ៍ ទៅជាអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០៤*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥១៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង នាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា

យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចលោកឧត្តមសេនីយ៍ទោ **ទាន់ ទាសនា** អត្តលេខ ០២៤៦ បច្ចុប្បន្នប្រធាននាយកដ្ឋានសណ្តាប់ - ធ្នាប់ អោយមកនៅនាយកដ្ឋានបុគ្គលិក នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចខាងក្រោម :

១- លោកឧត្តមសេនីយ៍ត្រី **ចំន្ទ ឫទ្ធី** អត្តលេខ ០០៣៣ បច្ចុប្បន្នអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ទៅជាប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ ។

២- លោកវរៈសេនីយ៍ឯក **យន់ ឆៃយ៉ា** អត្តលេខ ០០៨០ ជាអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៦៦ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខតំណែងនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាឱ្យដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ទោ **ឈុយ សារុន** អត្តលេខ ០០១៧ ជានាយករងសាលាគុបិទ្ធនគរបាល នៃក្រសួងមហាផ្ទៃ ជំនួសឯកឧត្តម ឧត្តមសេនីយ៍ឯក **សួរ ផន** ដែលមានមុខតំណែងពីរកន្លែង ។

**មាត្រា ២ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥១ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ចនាយនគរបាលជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចលោកឧត្តមសេនីយ៍ត្រី **សួន វណ្ណសារ៉ាយ** អត្តលេខ ០០២៩ បច្ចុប្បន្នអនុប្រធានទី ១ នាយកដ្ឋាននគរបាលព្រំដែនគោក អោយមកនៅនាយកដ្ឋានបុគ្គលិក នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ. ថ្ងៃទី ២៧ ខែ.កញ្ញា ឆ្នាំ ២០០៤*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥១៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចខាងក្រោម :

១- លោកវរៈសេនីយ៍ទោ **ហ៊ាខ នេខ** អត្តលេខ ០៣៥១៩ ។
២- លោកវរៈសេនីយ៍ទោ **ឈួន សុផល** អត្តលេខ ១៦០២៩ ។
៣- លោកវរៈសេនីយ៍ទោ **ម៉ុខ មីក់** អត្តលេខ ១៦០៣៧ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥១៩ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខនស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលរាជធានីភ្នំពេញ

## សម្រេច

**មាត្រា ១.** -

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០២ គ្រឿង ជូនសប្បុរសជន ជនជាតិជប៉ុន ០២ រូប ដែលបានចូលរួមអនុវត្តការផ្តល់ជំនួយឥតសំណង របស់រាជរដ្ឋាភិបាលជប៉ុន ក្នុងគំរោងការពារទឹកជំនន់ និង កែលំអប្រព័ន្ធប្រឡាយ-លូ ក្នុងរាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោម ៖

**1-Mr. Hideaki MUROYA President of Kubota Construction Co., Ltd**

**2-Mr. Katsuhisa ABE Chairman of CTI Engineering International Co., Ltd**

**មាត្រា ២.** -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច /
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៥៤០.អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខនស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាឱ្យដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលរាជធានីភ្នំពេញ

## សម្រេច

**មាត្រា ១.** -

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **និមមិទ្ធ** ចំនួន ០១ គ្រឿង ជូន **Mr.Juro CHIKARAISHI Resident Representative JICA Cambodia Office** ដែលបានដឹកនាំការអនុវត្តគំរោង ជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន ក្នុងគំរោងការពារទឹកជំនន់ និង កែលំអប្រព័ន្ធប្រឡាយ - លូ ក្នុងរាជធានីភ្នំពេញ ។

**មាត្រា ២.** -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៤១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខនស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលរាជធានីភ្នំពេញ

## សម្រេច

**មាត្រា ១.** -

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ចំនួន ០៩ គ្រឿង ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការសាលាក្រុងភ្នំពេញ ចំនួន ០៩ រូប ដែលបានចូលរួមក្នុងការ អនុវត្តគំរោងការពារទឹកជំនន់ និង កែលំអប្រព័ន្ធប្រឡាយ-លូ ក្នុងរាជធានី - ភ្នំពេញ ដូចមានរាយ នាមខាងក្រោម ÷

**ក-មេដាយមាសការងារ :**

១-ឯកឧត្តម **សេង គុង** អភិបាលរងរាជធានីភ្នំពេញ
២-ឯកឧត្តម **ព្រាក់ ខែរសៀង** អភិបាលរងរាជធានីភ្នំពេញ
៣-លោក **ហេង ទន្ថា** នាយរងខុទ្ទកាល័យសាលាក្រុងភ្នំពេញ
៤-លោកស្រី **គីម ទន្ទុនធីតា** នាយរងខុទ្ទកាល័យសាលាក្រុងភ្នំពេញ
៥-លោក **អ៊ុំ ម៉ារ៉ិន** អភិបាលរងខណ្ឌមានជ័យ

**ខ-មេដាយប្រាក់ការងារ :**

១-លោក **មាស ចន្ថា** ប្រធានអង្គភាពទំនប់-ច្រាំងទន្លេ នៃ ម.ស.រ
២-លោក **ដួង ចន្ទសារ៉ាន** អនុប្រធានអង្គភាពលូទឹក-បូមទឹក នៃ ម.ស.រ
៣-លោក **ជា ទន្ថា** មន្ត្រីការិយាល័យសាធារណការ នៃ ម.ស.រ
៤-កញ្ញា **ផៃ ធានី** មន្ត្រីការិយាល័យសាធារណការ នៃ ម.ស.រ

**មាត្រា ២.** -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥២២ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខងារនាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានតែងតាំងមុខងារ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាម ដូចខាងក្រោម ៖

១. ឧត្តមសេនីយ៍ឯក **ជៀន ជែល** អត្តលេខ ០០០០១៣ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

២. ឧត្តមសេនីយ៍ត្រី **មិន សារឿន** អត្តលេខ ០០០២០០ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

៣. ឧត្តមសេនីយ៍ត្រី **ឃិន យាន** អត្តលេខ ០០០១៣៩ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

៤. ឧត្តមសេនីយ៍ត្រី **ស្វូ ជី** អត្តលេខ ០០០២០១ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

៥. ឧត្តមសេនីយ៍ត្រី **ឃុន តីឈួប** អត្តលេខ ០០០១៩៩ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

៦. ឧត្តមសេនីយ៍ត្រី **ឃុត សំអាន់** អត្តលេខ ០០០១៩៦ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

៧. ឧត្តមសេនីយ៍ត្រី **ជាវ សុខលាង** អត្តលេខ ០០០៧៩២ មេបញ្ជាការរងបញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការដ្ឋាន

ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៥៧៤ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៣២អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតក្រុមប្រឹក្សាអ្នកច្បាប់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១.-**

ត្រូវបានតែងតាំងថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអ្នកច្បាប់ ដែលមានរាយនាមដូចខាងក្រោម :

១-លោក **សុខ ឌុល** សមាជិកអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអ្នកច្បាប់ មានឋានៈស្មើប្រធាននាយកដ្ឋាន

២-លោក **សុន ពិសិដ្ឋ** សមាជិកអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអ្នកច្បាប់ មានឋានៈស្មើប្រធាននាយកដ្ឋាន

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ កញ្ញា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥២៥ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
- យោងតាមសំណូមពរការងារចាំបាច់

## សម្រេច

**មាត្រា ១** : តែងតាំងលោកស្រី **គុយ ពិសី** ជាជំនួយការអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានឋានៈស្មើអគ្គនាយករង ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ_កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. ១៩៧ MOC / M 2004

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៤

## ប្រកាស

## ស្តីពី ការផ្តល់ឡើងវិញនូវនីតិបុគ្គលិកលក្ខណៈ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយ ប្រើដោយច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយ ប្រើដោយច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម
- យោងសំណើរបស់ក្រុមហ៊ុនលេខ ០០១ - ០៤ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៤
- យោងប័ណ្ណចំណូលលេខ ០០០៤៤៥ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៤
- យោងប័ណ្ណប៉ាតង់ ឆ្នាំ ២០០៤ និង លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធ របស់នាយកដ្ឋានពន្ធដារ លេខ ០៤៥៦៩១ និង ០៤៥៦៩៤

## សំរេច

**ប្រការ ១ :** ផ្តល់នីតិបុគ្គលិកលក្ខណៈឡើងវិញ ដល់ក្រុមហ៊ុន INTECH FOOTWEAR INDUSTRY Co., LTD ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Inv.៣៤៩ ៩៧ E ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៩៧ ចាប់ពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៤ តទៅ ។

**ប្រការ ២:** នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋាននីតិកម្ម ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស ប្រធានមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ ត្រូវអនុវត្តតាមប្រកាសនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចាម ប្រសិទ្ធ

**ចំលងជូន**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **លោ ណាំហុង**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលាក្រុងភ្នំពេញ
- ដូចបានចែងក្នុងប្រការ ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**KINGDOM OF CAMBODIA**

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. ១៩៤ MOC / M 2004

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៤

## ប្រកាស

### ស្តីពី ការផ្តល់ឡើងវិញនូវនីតិបុគ្គលិកលក្ខណៈ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយ ប្រើដោយច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយ ប្រើដោយច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម
- យោងសំណើរបស់ក្រុមហ៊ុនលេខ ១៦៨ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៤
- យោងប័ណ្ណចំណូលលេខ ០០០៤៥០ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៤
- យោងប័ណ្ណប៉ាតង់ ឆ្នាំ ២០០៤ និង លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធ ប្រចាំខែ សីហា របស់នាយកដ្ឋានពន្ធដារ

### សំរេច

**ប្រការ ១ :** ផ្តល់នីតិបុគ្គលិកលក្ខណៈឡើងវិញ ដល់ក្រុមហ៊ុន HANG NEAK VIDEO TAPE & IMPORT EXPORT LTD ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ ២០២៥ ៩៦ ៤ ចុះថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ១៩៩៦ ចាប់ពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៤ តទៅ ។

**ប្រការ ២:** នាយិកាខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានទីផ្សារកម្ម ប្រធាននាយកដ្ឋានគាំពារត្រួល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស ប្រធានមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ ត្រូវអនុវត្តតាមប្រកាសនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម_ប្រសិទ្ធ

**ចំលងជូន**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលាក្រុងភ្នំពេញ
- ដូចបានចែងក្នុងប្រការ ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones (855-12) 933 323 / 881223 Facsimile (855-23) 426396

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
លេខ : 3/4៥8 សណ

# ប្រ កា ស
## ស្តីពី
## ដែនកំណត់ចំណតនៃជលយាន
**************
## រដ្ឋមន្ត្រី
## ក្រសួងសាធារណការ និងដឹកជញ្ជូន

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-០៧០៤-១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើត ក្រសួងសាធារណការ និងដឹកជញ្ជូន

-បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងសាធារណការ និងដឹកជញ្ជូន

-បានឃើញអនុក្រឹត្យលេខ ០២ អ.ន.ក្រ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៨៦ ស្តីពីការកំណត់បណ្ឌលអាជីវកម្មកំពង់ផែ ស្វយ័តភ្នំពេញ

-បានឃើញអនុក្រឹត្យលេខ ៥១ អ.ន.ក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតកំពង់ផែស្វយ័តភ្នំពេញ

-បានឃើញអនុក្រឹត្យលេខ ៦៤ អ.ន.ក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រង ទីស្នាក់ការត្រួតពិនិត្យ ច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា

-អនុសញ្ញាអន្តរជាតិស្តីពី សុវត្ថិភាពជីវិតមនុស្សក្នុងនាវាចរណ៍ឆ្នាំ១៩៧៤ និងវិសោធនកម្មនានានៃ អនុសញ្ញានេះ

-ដើម្បីបង្កើន និងពង្រឹងនូវវិធានការគ្រប់គ្រងសន្តិសុខ សុវត្ថិភាពនាវា សន្តិសុខផែ និងរៀបចំសណ្តាប់ធ្នាប់បណ្តាជលយានយន្ត នានា

## សម្រេច

**ប្រការ១:** រាល់នាវាពាណិជ្ជកម្ម នាវាទេសចរណ៍ ទាំងអស់ដែលធ្វើការដឹកជញ្ជូនតាមផ្លូវទឹកជាលក្ខណៈអន្តរជាតិ ចូលមកកាន់ព្រះរាជាណាចក្រកម្ពុជា ត្រូវចូលចតនៅកំពង់ផែអន្តរជាតិភ្នំពេញ ដែលជាផែគោលដៅ ។ ការចូលចតក្រៅពីផែគោលដៅចាំបាច់ត្រូវមានការអនុញ្ញាតពីកំពង់ផែជាមុន ។

**ប្រការ២**៖ ជលយានយន្តក្នុងស្រុក និងអន្តរជាតិ ដែលកំពុងធ្វើអាជីវកម្ម ឬប្រើប្រាស់ផ្ទៃទឹកដែលស្ថិតនៅក្នុងមណ្ឌលអាជីវកម្មរបស់កំពង់ផែស្វយ័តភ្នំពេញ មានភារកិច្ចបង់ពន្ធតាមប្រកាសអន្តរក្រសួង លេខ ៥៦១ សហវ.ករ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០២ និងសេចក្តីសំរេចលេខ ១១០ សសរ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការ ប្រកាសអោយប្រើសេចក្តីសំរេចស្តីពីការយកពន្ធ និងថ្លៃឈ្នួលផែ ពីនាវាបរទេស ។

**ប្រការ៣**៖ កំពង់ផែស្វយ័តភ្នំពេញ ត្រូវមានវិធានការទប់ស្កាត់ចំពោះការប្រព្រឹត្តល្មើសនៃមធ្យោបាយដឹកជញ្ជូន នានាដូចជា ការលេងល្បែងស៊ីសង ឬ ល្បែងផ្សេងៗ សកម្មភាពការរំលោភ ដែលធ្វើអោយប៉ះពាល់សណ្តាប់ធ្នាប់ សុវត្ថិភាព សន្តិសុខ និងបរិស្ថានផងដែរ ។

**ប្រការ៤**៖ នាយកខុទ្ទកាល័យ អគ្គនាយកពន្ធដារ អគ្គនាយកដឹកជញ្ជូន អគ្គនាយកសាធារណការ អគ្គាធិការ អង្គភាពពាក់ព័ន្ធ និងអគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ មានភារកិច្ចអនុវត្តការងារតាមខ្លឹមសារប្រកាសនេះអោយមានប្រសិទ្ធិភាព ។

ភ្នំពេញ ថ្ងៃទី ២៩ ខែ ៩ ឆ្នាំ២០០៤

**រដ្ឋមន្ត្រី**

ស៊ុន ចាន់ថុល

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

"ដើម្បីជូនជ្រាប"
- សាលាក្រុងភ្នំពេញ
- សាលាខេត្តកណ្តាល
- សាលាខេត្តព្រៃវែង
- សាលាខេត្តកំពង់ចាម
- សាលាខេត្តកំពង់ឆ្នាំង
- សាលាខេត្តសៀមរាប

"ដើម្បីជ្រាប"
- កំពង់ផែស្វយ័តភ្នំពេញ

"ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ:.......១៥៩.........ប្រក/ដនស

# ប្រកាស
## ស្តីពី
## ឯកសណ្ឋាន និងសញ្ញាសំគាល់សំរាប់មន្ត្រី
## នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

* * * * *

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើរដ្ឋធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-យោងតាមការចាំបាច់របស់ក្រសួង

## សំរេច:

**ប្រការ១. –**

បង្កើត និងកំណត់ឯកសណ្ឋាន និងសញ្ញាសំគាល់សំរាប់មន្ត្រី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីប្រតិបត្តិការ និងចូលរួមក្នុងពិធីផ្លូវការផ្សេងៗ ។

**ប្រការ២. —**

ឯកសណ្ឋានមន្ត្រី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានកំណត់ដូចខាងក្រោម:

**ក ឯកសណ្ឋានសំរាប់បុរស:**

-អាវដៃខ្លី ឬដៃវែង អាវនីមួយៗមានពណ៌ស ឬពណ៌កាគី ចោះរន្ធឡេវមុខមានប៊ូលស្មាទាំងសងខាង មិនឱ្យរលុងពេក សំរុងជើងអាវត្រង់ស្មើ និងមានជីបខ្នង ១ សងខាង។ អាវនេះមានហោប៉ៅខាងលើពីរ (ដេរប៉ះ) បត់ផ្នត់កណ្តាលមួយ មានគំរបហោប៉ៅរាងស្លឹកពោធិ៍ និងដាក់ឡេវជ័រពណ៌ដូចអាវ។

-ខោជើងវែងពណ៌ទឹកប៊ិចចាស់ ដេរផ្ទេរបង្កប់ ចង្កេះត ជីបភ្លីខាងមុខពីរ មានហោប៉ៅបី។ ហោប៉ៅខាងក្រោយមួយដេរបង្កប់ មានគំរបរាងស្លឹកពោធិ៍ ចោះរន្ធដាក់ឡេវចំនួន ១ និងហោប៉ៅចំហៀងទាំងសងខាង ដេរបង្កប់តាមថ្នេរ។

—មួកមានពីរប្រភេទគឺ

**+ មួកការពារសុវត្ថិភាព:**

សំរាប់ពាក់ជាមួយឯកសណ្ឋានការងារនៅក្នុងការដ្ឋានសំណង់ ដែលផលិតឡើងអំពីជ័រមានពណ៌ស ។

**+ មួកកាស្កេត:**

សំរាប់ពាក់ជាមួយឯកសណ្ឋានការងារ ក្នុងពេលបំពេញបេសកកម្ម។មួកកាស្កេត ពណ៌កាគីមានក្បាំងមុខ និងនៅផ្នែកខាងលើមានដេរជីបរាងជាប្រាំបីជ្រុង ហើយមានចោះរន្ធពីរទាំងសងខាង។

—ស្បែកជើង កខ្លី ពណ៌ខ្មៅចងខ្សែ និងស្រោមជើងពណ៌ទឹកប៊ិចចាស់។

—ខ្សែក្រវ៉ាត់ពណ៌ខ្មៅ ។

**ខ.ឯកសណ្ឋានសំរាប់ស្ត្រី:**

-សំពត់ប្រឹបជីបីស្ទារ៉េ ពណ៌ទឹកប៊ិចចាស់ ពាក់កណ្តាលកំភួនជើង ចង្កេះតខាងមុខមានចាប់ផ្នត់ និងខាងក្រោយមានឆែក។

-អាវដៃវែង ឬដៃខ្លី អាវនីមួយៗមានកតាំង ឬកឌុប មានពណ៌ស និងពណ៌កាគី

-ស្បែកជើងពណ៌ខ្មៅគ្មានចងខ្សែ (អេស្កាបាំង) និងស្រោមជើងពណ៌ទឹកប៊ិចចាស់។

**ប្រការ៣. —**

ផ្លាកសញ្ញា និងផ្លាកឈ្មោះរបស់មន្ត្រីត្រូវបានកំណត់ដូចខាងក្រោម:

**១ អំពីផ្លាកសញ្ញាដាក់នៅលើដើមដៃអាវ**

ផ្លាកសញ្ញានេះមានពីរប្រភេទគឺ:

**ក ផ្លាកសញ្ញាសំគាល់ក្រសួង**

ផ្លាកសញ្ញានេះមានរាងមូលជារង្វង់( O ) មានអង្កត់ផ្ចិតប្រវែង៨ ស.ម មានរឹមខាងក្រៅពណ៌ទឹកប៊ិចចាស់ប្រវែង ០,១ ស.ម ។ រង្វង់ផ្នែកខាងក្នុងមានអង្កត់ផ្ចិតប្រវែង ៦ ស.ម រឹមខាងក្រៅមានប្រវែង ០,១ ស.ម ពណ៌ទឹកប៊ិចចាស់ ។ នៅក្នុងរង្វង់មានរូបដែកឈានពណ៌សរឹមពណ៌ខ្មៅ និងរូបផែនទីនៃព្រះរាជាណាចក្រកម្ពុជាមានផ្ទៃពណ៌ស រឹមពណ៌ក្រហម ឯផ្ទៃខាងក្រៅជុំវិញផែនទីមានពណ៌ផ្ទៃទឹកសមុទ្រ។ នៅចន្លោះរវាងរង្វង់ខាងក្រៅ និងខាងក្នុងមានប្រវែង ១ ស.ម និងមានផ្ទៃពណ៌ស ដែលផ្នែកខាងលើកោងតាមរង្វង់មានសរសេរអក្សរខ្មែរជាអក្សរមូលថា " **ព្រះរាជាណាចក្រកម្ពុជា** " ខ្នាត ៣៦ (Limon R1 Font size ៣៦ ) ពណ៌ទឹកប៊ិចហើយផ្នែកខាងក្រោមកោងតាមរង្វង់ មានសរសេរអក្សរខ្មែរជាអក្សរមូលថា" **ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**" ខ្នាត ១៨ ( Limon R1 Font size ១៨) ពណ៌ទឹកប៊ិច ផ្លាកសញ្ញានេះដាក់នៅដើមដៃអាវខាងឆ្វេង ។

**ខ ផ្លាកសញ្ញាសំរាប់មន្ត្រីថ្នាក់ខេត្ត ក្រុង**

ផ្លាកសញ្ញានេះមានរាងជាអក្សរអ៊ុយហ្វិច( U ) ពីលើចុះក្រោមមានប្រវែង៨,៥ ស.ម និងពីឆ្វេងទៅស្តាំមានប្រវែង ៧ ស.ម មានរឹមពីរជាន់ ពណ៌ទឹកប៊ិច ចន្លោះរវាងរឹមខាងក្រៅ និងខាងក្នុងមានប្រវែង ០,៥ ស.ម មានផ្ទៃពណ៌ស ។ នៅខាងក្នុងផ្នែកខាងលើនៃសញ្ញា( U ) មានសរសេរអក្សរថា"**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**" និងខាងក្រោមមានសរសេរថា"**មន្ទីរ ដ.ន.ស.ស** និងឈ្មោះខេត្តក្រុង"ដែលមានទំហំអក្សរខ្នាត២៤(Limon R1 Font size 24) នៅខាងក្នុងផ្នែកខាងក្រោមនៃសញ្ញា( U ) មានរូបសញ្ញារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ រូបសញ្ញានេះមានរាងមូលមានអង្កត់ផ្ចិតប្រវែង៤ស.ម រឹមខាងក្រៅមានប្រវែង ០,០៥ ស.ម ពណ៌ទឹកប៊ិចចាស់ ។ ក្នុងរង្វង់មូលមាន រូបដែកឈានពណ៌សរឹមពណ៌ខ្មៅ និងមានរូបផែនទីនៃព្រះរាជាណាចក្រកម្ពុជាដែលមានផ្ទៃពណ៌សរឹមពណ៌ក្រហមនិងផ្ទៃខាងក្រៅជុំវិញផែនទីមានពណ៌ផ្ទៃមេឃ ។ ផ្លាកសញ្ញានេះដាក់នៅដើមដៃអាវខាងស្តាំ បន្ថែមលើផ្លាកសញ្ញា សំគាល់ក្រសួងដែលដាក់នៅខាងឆ្វេង ។

**២ អំពីផ្លាកឈ្មោះ**

ផ្លាកឈ្មោះនេះមានពីរប្រភេទគឺ:

**ក សំរាប់មន្ត្រីថ្នាក់ក្រសួង**

ផ្លាកឈ្មោះសំរាប់ពាក់នៅលើហោប៉ៅអាវខាងស្តាំ មានរាងបួនជ្រុងទ្រវែងស្តើងយ៉ា

ប្រវែង ៩ ស.ម និងទទឹងប្រវែង ២.៥ ស.ម ធ្វើអំពីជ័ររឹងថ្លាមានពណ៌ទឹកសមុទ្រ និងមានខ្សែបន្ទាត់ពណ៌មាសទំហំ ០.១៥ ស.ម ព័ទ្ធជុំវិញ។ នៅខាងស្តាំនៃផ្លាកឈ្មោះ មានរូបសញ្ញាសំគាល់ក្រសួង មានរាងជារង្វង់ រំលេចដោយវ័ណ្ណ និង អក្សរពណ៌មាស (ដូចរូបសញ្ញានៅដើមដៃអាវខាងឆ្វេង) ដែលមានអង្កត់ផ្ចិតទំហំ ២ ស.ម ។

នៅខាងឆ្វេងនៃរូបសញ្ញានេះ ជួរខាងលើសរសេរនាមត្រកូល និងនាមខ្លួនជាអក្សរមូលខ្មែរ ពណ៌ទឹកមាសផុសថា " **លោក.**ទំហំ ២២ (Limon R1Font size 22) នាមត្រកូលនិងនាមខ្លួន ទំហំ៣០ (Limon R1Font size 30)" និងខាងក្រោមសរសេរនាមត្រកូលនិងនាមខ្លួនជាអក្សរឡាតាំង (Time New Roman) ពណ៌ទឹកមាសផុសថា" Mr. ទំហំ ១១ (Font size 11) នាមត្រកូល និង នាមខ្លួនទំហំ ១២ (Font size 12) " និងខាងក្រោមអក្សរឡាតាំងមានអត្តលេខសំគាល់មន្ត្រីរបស់ក្រសួង រវាងឈ្មោះនិងរូបសញ្ញា ខណ្ឌគ្នាដោយបន្ទាត់ឈរពណ៌មាសផុសទំហំ ០,១ ស.ម។

**ខ សំរាប់មន្ត្រីថ្នាក់ខេត្ត ក្រុង**

ផ្លាកឈ្មោះសំរាប់ពាក់នៅលើហោប៉ៅអាវខាងស្តាំ មានរាងបួនជ្រុងទ្រវែងបណ្តោយប្រវែង ៩ ស.ម និងទទឹង ២.៥ ស.ម ធ្វើអំពីជ័ររឹងថ្លាមានពណ៌ទឹកសមុទ្រ និងមានខ្សែបន្ទាត់ពណ៌មាសទំហំ ០.១៥ ស.ម ព័ទ្ធជុំវិញ។ នៅខាងស្តាំនៃផ្លាកឈ្មោះ មានរូបសញ្ញាសំគាល់មន្ត្រីថ្នាក់ខេត្ត ក្រុង មានរំលេចដោយវ័ណ្ណ និង អក្សរពណ៌មាស (ដូចរូបសញ្ញានៅដើមដៃអាវខាងឆ្វេង) ដែលមានកំពស់ពីលើចុះក្រោមប្រវែង ២ ស.ម និង ពីឆ្វេងទៅស្តាំប្រវែង ១.៥ ស.ម។

នៅខាងឆ្វេងនៃរូបសញ្ញានេះ ជួរខាងលើសរសេរនាមត្រកូល និង នាមខ្លួនជាអក្សរមូលខ្មែរ ពណ៌ទឹកមាសផុសថា " **លោក.**ទំហំ ២២ (Limon R1 Font size 22) នាមត្រកូលនិងនាមខ្លួន ទំហំ៣០ (Limon R1Font size 30)" និងខាងក្រោមសរសេរនាមត្រកូលនិងនាមខ្លួនជាអក្សរឡាតាំង (Time New Roman) ពណ៌ទឹកមាសផុសថា" Mr. ទំហំ ១១ (Font size 11) នាមត្រកូល និងនាមខ្លួនទំហំ១២ (Font size 12) "និងខាងក្រោមអក្សរឡាតាំងមានអត្តលេខសំគាល់មន្ត្រីរបស់ខេត្ត ក្រុង រវាងឈ្មោះនិងរូបសញ្ញា ខណ្ឌគ្នាដោយបន្ទាត់ឈរពណ៌មាសផុសទំហំ ០.១ ស.ម។

**ប្រការ៤. –**

ឯកសណ្ឋានការងារមន្ត្រីបច្ចេកទេសនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ដើម្បីបំពេញការងារក្នុងការិយាល័យ

ធ្វើការ ពុំចាំបាច់ប្រើប្រាស់មួកទាំងពីរប្រភេទខាងលើនេះទេ ។

**ប្រការ៥. –**

ឯកសណ្ឋានការងារពីរសម្រាប់គឺ ដៃវែង ១ សម្រាប់ និងដៃខ្លី ១ សម្រាប់ សំរាប់រយៈពេល ១ ឆ្នាំ ដើម្បីប្រើប្រាស់បំពេញការងារប្រចាំថ្ងៃ ប្រជុំការងារ ទិវាបុណ្យជាតិ និងប្រតិបត្តិការត្រួតពិនិត្យការងារជំនាញ ។

**ប្រការ៦. –**

ជនណាក្លែងបន្លំស្លៀកពាក់ឯកសណ្ឋាន និងសញ្ញាសំគាល់របស់មន្ត្រីនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**ប្រការ៧. –**

នាយកខុទ្ទកាល័យ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន ប្រធានអង្គភាពចំណុះក្រសួង និងប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី គ្រប់ខេត្ត ក្រុង ត្រូវអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ, ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អ៊ឹម ឈុនលឹម**

**ចំលងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ៧
- ឯកសារ កាលប្បវត្តិ




# ផ្លាកសញ្ញាសំគាល់ក្រសួង




ផ្លាកឈ្មោះសំរាប់ពាក់ភ្ជាប់ផ្នែកខាងលើហោប៉ៅអាវខាងស្តាំ
សំរាប់មន្ត្រីថ្នាក់កណ្តាល

-ឈ្មោះពណ៌ទឹកមាស អក្សរផុស
-ស៊ុមពណ៌ទឹកមាស ផុស




រូបសញ្ញាមួកសំរាប់ការដ្ឋានសំណង់




ផ្លាកសញ្ញាដេរភ្ជាប់ដៃអាវខាងឆ្វេង










# ផ្លាកសញ្ញាសំរាប់មន្ទីរខេត្ត ក្រុង




**ផ្លាកឈ្មោះសំរាប់ពាក់ភ្ជាប់ផ្នែកខាងលើហោប៉ៅអាវខាងស្តាំ សំរាប់មន្ត្រីថ្នាក់ ខេត្ត ក្រុង**

-ឈ្មោះពណ៌ទឹកមាស អក្សរផុស

-ស៊ុមពណ៌ទឹកមាស ផុស




**រូបសញ្ញាលើមួកសំរាប់ការដ្ឋានសំណង់**




**ផ្លាកសញ្ញាដេរភ្ជាប់ដៃអាវខាងស្តាំ សំរាប់មន្ត្រីថ្នាក់ ខេត្ត ក្រុង**





**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ០៤៧/០៤ ក.អ.ជ ប្រ.ក

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៤

## ប្រកាស

## ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងគំរោង និងតែងតាំងនាយកគំរោង និងអ្នកគ្រប់គ្រងគំរោងសំរាប់បំរើការងារនៅអង្គភាពគ្រប់គ្រងគំរោង ក្នុងក្របខ័ណ្ឌឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នៃគំរោងផ្គត់ផ្គង់ទឹកជនបទ និងអនាម័យ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ន.ស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសអោយប្រើនូវច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញសេចក្តីសំរេចលេខ ១៧៩១ សសរ/អជប ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបែងចែកភារកិច្ច និង ការកំណត់របៀបរបបធ្វើការរបស់ថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ
- អនុស្សរណៈយោគយល់គ្នារវាង ADB's Mission ជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ដែលបានចុះហត្ថលេខានៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០២
- យោងតាមតំរូវការចាំបាច់

## សំរេច

ប្រការ១: បង្កើតឡើងនូវអង្គភាពគ្រប់គ្រងគំរោង (PMU) សំរាប់អនុវត្តគំរោងឥណទាន នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលមានទីស្នាក់ការនៅ នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ ។

ប្រការ២: តែងតាំងនាយកគំរោង (Project Director) និង អ្នកគ្រប់គ្រងគំរោង (Project Manager) សំរាប់អនុវត្តគំរោងផ្គត់ផ្គង់ទឹកជនបទ និងអនាម័យ ក្នុងខេត្តកំពង់ធំ ខេត្តកំពត និងខេត្តពោធិសាត់ ក្នុងក្របខ័ណ្ឌឥណទាន នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលមានសមាសភាពដូចខាងក្រោម:

១- លោក **ម៉ៅ សារ៉ាយ** នាយកគំរោង

២- លោក **នួន តេជ្រនិមិត្ត** អ្នកគ្រប់គ្រងគំរោង

ប្រការ៣: មន្ត្រីដូចមានចែងក្នុងប្រការ ២ មានភារកិច្ចទទួលខុសត្រូវ ក្នុងការអនុវត្តគំរោង ក្នុងក្របខ័ណ្ឌឥណ ទាន នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដូចមានចែងក្នុងឯកសារគំរោង ។

ប្រការ៤: អគ្គនាយកទាំងពីរ អគ្គាធិការ ខុទ្ទកាល័យ គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួង មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ ខេត្តកំពត និង ខេត្តពោធិសាត់ និង សាម៉ីជនដូចមានចែងក្នុងប្រការ២ មានភារកិច្ចអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**

**ជា សាមុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ កំពត និង ពោធិសាត់
- ធនាគារអភិវឌ្ឍន៍អាស៊ី ADB

  ដើម្បីជូនជ្រាប:
- ដូចមានចែងក្នុងប្រការ ៤

  ដើម្បីអនុវត្ត:
- ឯកសារ-កាលប្បវត្តិ